ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១២៧
ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៤

# សាលដីកា

លេខ : ៩៨
ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | រៀល មួន | ចៅក្រម |
| ៤- លោក | យស់ សូខឿន | ចៅក្រមរបាយការណ៍ |
| ៥- លោកស្រី | គីម សត្ថាវី | ចៅក្រម |
| លោក | គីម ថារ៉ូ | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ៥៦"ក" ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១២៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

- **<u>ពីបទ</u>**:ជេរប្រមាថ និងរំលោភលើសិទ្ធិបុគ្គល កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ តាមបញ្ញត្តិមាត្រា៦៣.៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះម៉ម ម៉ារី (ម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ប្រធានប៉ុស្តិ៍នគរបាល ឃុំស្រឡៅ ទីលំនៅសព្វថ្ងៃភូមិហាន់ទ្វារ ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឪពុកឈ្មោះ សៅ ប៊ូច (ស) ម្តាយឈ្មោះ គីម សំអាត (រ) ប្រពន្ធឈ្មោះជួប ធារី មានកូន០៤នាក់ ។ ក្រៅឃុំ ។

-មេធាវី : គ្មាន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ខុំ (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅសព្វថ្ងៃភូមិរំចេក ឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

-មេធាវី : គ្មាន

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់ឈ្មោះ ជុំ ខុំ ប្តឹងពីឈ្មោះ ម៉ម មារី ប្រធាននគរបាលប៉ុស្តិ៍ស្រឡៅ និង បក្សពួកដោយសំអាងហេតុថា នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ វេលាម៉ោង ៧:៣០នាទីព្រឹក លោក ម៉ម មារី និងលោក មុំ ហន បានយកអាវុធរបស់ខ្លួន បើកសោ ហើយភ្ជង់សំឡុត នឹងដៀលត្មេះខ្លួន ដើម្បីយកលុយ៣០០.០០០៛ ដោយប្រើពាក្យថា បើហែងឯងមិន យកលុយ ៣០០.០០០៛ អោយអញទេ អញបាញ់ហែងឯងចោល គឺនិយាយក្នុងចំណោមមនុស្សជា ច្រើន ។មូលហេតុដែលនិយាយនេះ គឺដោយសារវាចង់យកលុយរបស់សមូហភាពដែលទុកបែងចែក ឱ្យកំលាំងការពារសន្តិសុខគ្រប់គ្រង និងចាយខ្លួនឯង ចំពោះលុយនេះដែរ ឈ្មោះម៉ម មារី នេះ មិនត្រូវកាន់ខ្លួនឯងទេ គឺបានប្រគល់ភារកិច្ចអោយទៅនគរបាលស្រុកជាអ្នកគ្រប់គ្រង មិនតែប៉ុណ្ណោះ គេក៏យកអាវុធទៅភ្ជង់ឈ្មោះទុំ ចំរើន ជាអ្នកដឹកនាំក្រុមប៉ូលីស ឡើងជញ្ជាំងទារលុយ និងភ្ជង់ឈ្មោះ ប៊ូ ហួត ដែលជាអ្នកធ្វើកង់ និងជាអ្នកបើកលែងល្បែងប្រជាប្រិយ៍ នៅវត្តឧទុម្ពរ ក្នុងពេលបុណ្យនេះ ក្រោយពីពួកគេមិនប្រគល់លុយឱ្យឈ្មោះនេះ រឹតតែស្រែកតេះដៀលខ្លួន យ៉ាងខ្លាំងកណ្តាលចំណោម មនុស្ស ហើយបាញ់កាំភ្លើងចំនួន០២គ្រាប់ សំឡុតថែមទៀត ធ្វើឱ្យខ្លួនរត់គេច ដើម្បីប្តឹងសមត្ថកិច្ច ឱ្យគេជួយ ។ក្នុងរឿងនេះខ្លួនសុំឱ្យឈ្មោះម៉ម មារី សងជំងឺចិត្តចំនួន៥.០០០.០០០ (ប្រាំលានរៀល) ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកំពង់ធំបានសំរេច :

ចោទប្រកាន់លើឈ្មោះ ម៉ម មារី ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ កើតនិងទីលំនៅ សព្វថ្ងៃ ភូមិហាន់ទ្វារ ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ មុខរបរនាយប៉ុស្តិ៍រដ្ឋបាល ឃុំស្រឡៅ ប្រពន្ធ ឈ្មោះជួប ធារី មានកូន០៤នាក់ ឪពុកឈ្មោះ សៅ ប៊ូច (ស) ម្តាយឈ្មោះ អោម អឿន (រ) ទោសពីមុនគ្មាន ។

ពីបទ: ជេរប្រមាថ និងរំលោភលើសិទ្ធិបុគ្គល ប្រព្រឹត្តនៅភូមិវត្តឧទុម្ពរ ឃុំស្រឡៅ ស្រុក បារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ តាមបញ្ញត្តិ មាត្រា៦៣.៩៧ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១១២០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ របស់ តុលាការខេត្តកំពង់ធំ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-ផ្តន្ទាទោសឈ្មោះ ម៉ម ម៉ារី ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ពិន័យជាប្រាក់ ៣ម៉ឺនរៀល (៣០០០០៛០០) ពីបទជេរប្រមាថ ចាប់ពីថ្ងៃសាលក្រមស្ថាពរតទៅ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ។

-ដាក់ពន្ធនាគារកំនត់១ឆ្នាំ តែទោសនេះត្រូវព្យួរសាកល្បង៥ឆ្នាំ ពីបទៈជេរប្រមាថ និងរំលោភលើសិទ្ធិបុគ្គល ប្រព្រឹត្តនៅភូមិវត្តឧទុម្ពរ ឃុំស្រឡៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៦៣ និង ៣៧.៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-វត្ថុតាងសំបកឡុត AK ២ ត្រូវរឹបអូស និងបំផ្លាញចោល

៣-បង្គាប់ឱ្យឈ្មោះ ម៉ម ម៉ារី សងជូសជុលការខូចខាត និងជំងឺចិត្តជាប្រាក់ចំនួន ៨០ម៉ឺនរៀល ឱ្យទៅឈ្មោះជុំ ខុំ ចាប់ពីថ្ងៃសាលក្រមនេះ ចូលជាស្ថាពរតទៅ បើឈ្មោះម៉ម ម៉ារី រឹងទទឹង មិនព្រមបង់ប្រាក់នេះទេ ត្រូវចាប់ដាក់គុកបង្ខំលើរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៤-សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងឈ្មោះជុំ ខុំ និងជនល្មើសឈ្មោះម៉ម ម៉ារី បើភាគីមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥៣ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះម៉ម ម៉ារី ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ១២០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ របស់តុលាការខេត្តកំពង់ធំ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា:

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៥៣ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះម៉ម ម៉ារី ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១២០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ របស់តុលាការខេត្តកំពង់ធំ បានការតទៅ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៥៦"ក" ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០១ របស់ជនជាប់ចោទឈ្មោះម៉ម ម៉ារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ខុស និងគតិច្បាប់ ។

២-តម្កល់សាលក្រមលេខ១២០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ របស់តុលាការខេត្តកំពង់ធំ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៩០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះម៉ម មារី ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៥៦"ក" ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះម៉ម មារី

-បានឃើញសារណាតប ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះជុំ ខុំ

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

+ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះម៉ម មារី ពិតជាបានជេរប្រមាថ និងរំលោភលើសិទ្ធិបុគ្គល កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ នៅភូមិហាន់ទ្វា ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦៣, ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

+ បណ្តឹងសាទុក្ខរបស់ឈ្មោះ ម៉ម មារី ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

+ សាលដីកាព្រហ្មទណ្ឌលេខ៥៦"ក" ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់សាលឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាការពារ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះម៉ម មារី

-បានស្តាប់ក្រឡាបញ្ជីអានសារណាតប ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៦ របស់ឈ្មោះជុំ ខុំ

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : ពុំមានអ្វីបន្ថែមទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៩០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះម៉ម ម៉ារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះម៉ម ម៉ារី ពីបទជេរប្រមាថ និងរំលោភលើសិទ្ធិបុគ្គល ប្រព្រឹត្តនៅវត្តឧទុម្ពរ ឃុំស្រឡៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ ។

-យល់ឃើញថា ការលើកឡើងរបស់ឈ្មោះ ម៉ម ម៉ារី ក្នុងសារណាថា ខ្លួនពុំបានជេរប្រមាថ និងរំលោភសិទ្ធិលើបុគ្គល ជុំ ខុំ ទេ គឺខ្លួនគ្រាន់តែបាញ់តំរាមមិនអោយឡានដឹកឥវ៉ាន់ចេញប៉ុណ្ណោះ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះមានភស្តុតាងជាសាក្សី ជាច្រើនបានឆ្លើយបញ្ជាក់ថា ឈ្មោះនេះពិតជាបានជេរប្រមាថ ជនរងគ្រោះនៅទីលានសាធារណៈ ហើយការបាញ់តំរាមនេះ ជាការរំលោភលើសិទ្ធិបុគ្គលហើយ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចតុលាការខេត្តកំពង់ធំដែរ ដែលសំរេចញែកទោសក្នុងអំពើប្រព្រឹត្ត របស់ជនជាប់ចោទនេះ ជាការពុំត្រឹមត្រូវទេ ពីព្រោះបទល្មើសទាំងពីរនេះ ប្រព្រឹត្តឡើងដោយមនុស្សតែម្នាក់ទៅលើជនរងគ្រោះតែម្នាក់ និងក្នុងកាលៈទេសៈតែមួយ ដែលគប្បីសំរេចអោយស្រូបទោស ប៉ុន្តែដោយការផ្តន្ទាទោស មានលក្ខណៈត្រឹមត្រូវហើយ គប្បីតុលាការកំពូលសំរេចតម្កល់ទុកជាបានការ ។

-យល់ឃើញថា ក្នុងការសំរេចពិន័យជាប្រាក់ក្រោមអប្បបរិមា នៃទោសតុលាការខេត្តកំពង់ធំ បានបំពានទៅ និងមាត្រា៦៣ (ចាស់) នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដោយព្រះរាជអាជ្ញា ពុំបានប្តឹងឧទ្ធរណ៍ ដូច្នេះតុលាការកំពូល ពុំអាចពិចារណាបានទេ ។

-យល់ឃើញថា ទាំងជនជាប់ចោទ ទាំងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួន ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៦"ក" ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ និង

### ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ៩០ ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះម៉ម ម៉ារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស និងគតិច្បាប់ ។